**សេចក្តីថ្លែងការណ៍រួម – កម្ពុជា** MEF 06

នេះគឺជាសេចក្តីថ្លែងការណ៍រួមរវាងធនាគារ ខេប៊ី ប្រាសាក់ និងអ្នកដាក់ពាក្យបណ្តឹង ពាក់ព័ន្ធនឹងការវិនិយោគដោយប្រយោលរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ជាមួយធនាគារ ខេប៊ី ប្រាសាក់ តាមរយៈទំនាក់ទំនងផ្នែកហិរញ្ញវត្ថុរបស់ពួកគេជាមួយ MEF (គម្រោងរបស់ IFC លេខ #27827)។ ពាក្យបណ្តឹងនេះត្រូវបានសម្គាល់ថា «កម្ពុជា MEF 06»។

ក្នុងអំឡុងពេលនៃដំណើរការវាយតម្លៃរបស់ការិយាល័យ ស៊ី.អេ.អូ អ្នកដាក់ពាក្យបណ្តឹង និងអតិថិជនបន្តរបស់ IFC គឺធនាគារ ខេប៊ី ប្រាសាក់ បានបង្ហាញចំណាប់អារម្មណ៍ចូលរួមក្នុងដំណើរការដោះស្រាយវិវាទ ដែលមានការសម្របសម្រួលពីការិយាល័យ ស៊ី.អេ.អូ ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង ពាក់ព័ន្ធនឹងធនាគារ ខេប៊ី ប្រាសាក់ ដោយប្រើប្រាស់វិធីសាស្រ្តសហការ។ ភាគីទាំងពីរបានឯកភាពគ្នាលើគោលការណ៍ជាមូលដ្ឋាន សម្រាប់ការសម្រុះសម្រួល នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៥។ ជាលទ្ធផលនៃការចូលរួមដោះស្រាយវិវាទដោយស្ម័គ្រចិត្តនេះ ភាគីទាំងពីរបានឈានដល់ និងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយផ្នែកនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៥ និងកិច្ចព្រមព្រៀងចុងក្រោយនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៥ ហើយបានឯកភាពគ្នាថា ការិយាល័យ ស៊ី.អេ.អូ នឹងពិនិត្យតាមដានការអនុវត្តកិច្ចព្រមព្រៀងដោះស្រាយវិវាទនេះ រហូតដល់ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៧ ដោយមានលទ្ធភាពបន្តរយៈពេលពិនិត្យតាមដាននេះ។